# ការសំភាសន៍របស់លោកពូ ប៉ែន ជា

**កៈអ្នកដែលសំភាសន៍ឈ្មោះ ថន រដ្ឋា        ខៈអ្នកដែលត្រូវបានគេសំភាសន៍ឈ្មោះ ប៉ែន ជា**

កៈ បាទ! ថ្ងៃនេះជាថ្ងៃទី២ ខែ មេសា ឆ្នាំ២០១៨។ ខ្ញុំបាទឈ្មោះ ថន រដ្ឋា និងធ្វើការសំភាសន៍លោកពូជាដែលបច្ចុប្បន្នលោកពូរស់នៅភូមិចំការសំរោងពីរ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបូង អញ្ចឹងលោកពូសូមជួយជំរាបឈ្មោះពេញរបស់លោកពូផង។

ខៈ ខ្ញុំបាទឈ្មោះប៉ែន ជា។

កៈ លោកពូមានឈ្មោះហៅក្រៅទេលោកពូ។

ខៈ អត់មានទេ។

កៈ កាលពីក្មេង។

ខៈ អត់ដែរមានតែឈ្មោះតែមួយទេ។

កៈ លោកពូឆ្នាំហ្នឹងអាយុប៉ុន្មានហើយ។

ខៈ ៥៦ ឆ្នាំ។

កៈ លោកពូកើតឆ្នាំអី។

ខៈ ឆ្នាំមមែ។

កៈ ហើយទីកន្លែងកំណើតកើតនៅឯណាដែរ។

ខៈ កើតនៅភូមិថ្មី ឃុំកន្ទឿមួយ ស្រុកបាណន់ ខេត្តបាត់ដំបង។

កៈ លោកពូមានបងប្អូនប៉ុន្មាននាក់។

ខៈ បងប្អូនទាំងអស់៦នាក់។

ក៖ លោកពូអាចជួយប្រាប់បានទេថាលោកូជាកូនទីប៉ុន្មានដែល។

ខ៖ កូនទីប្រាំ។

ក៖ សំរាប់បងប្អូនផ្សេងទៀតគាត់មានឈ្មោះអ្វីដែល។

ខ៖ បងទីមួយឈ្មោះកែម សំនឿន។ បងទីពីរឈ្មោះកែម បាវ។ បងទីបីឈ្មោះកែម លីម។បងទីបួនឈ្មោះកែម លើប។ហើយខ្ញុំទីប្រាំឈ្មោះកែម ជា ហើយទីប្រាំមួយឈ្មោះកែម ចៃវ។

ក៖ មិនមែនកែម លីទេណោះ។

ខ៖ មិនមែនទេត្រកូលដូចគ្នា។

ក៖ ហើយពួកគាត់ទាំងអស់គ្នាសព្វថ្ងៃរស់នៅឯណាដែលម្នាក់ៗ។

ខ៖ ពួកគាត់ទទួលមរណភាពអស់ហើយ(ស្លាប់អស់ហើយ)។

ក៖ ទាំងអស់គ្នាហ្នឹង។

ខ៖ សូម្បីតែឪពុកម្តាយទាំងអស់គ្នានៅតែខ្ញុំមួយនាក់ឯងទេ។

ក៖ ហើយសំរាប់លោកពូផ្ទាល់លោកពូមានចងចាំរឿងកំសត់កម្រកាលពីនៅក្មេងៗទេ។

ខ៖ កាលនោះខ្ញុំនៅតូចតែខ្ញុំធ្លាប់ឆ្លងកាត់ជាមួយបងស្រីខ្ញុំឈ្មោះកែម លើបហើយប្អូនប្រុសខ្ញុំមួយទៀតកាលនោះក្នុងរបបពុលពតពេលហ្នឹងកំសត់ណាស់បងប្អូនបែកគ្នាអស់បន្ទាប់ឈ្មោះកែម ច័ន្ទគាត់ស្លាប់នៅជំនាន់ពុកពតហើយបងស្រីខ្ញុំមួយទៀតនេះតែគាត់ស្លាប់ក្នុងឆ្នាំ១៩៨៨។ កាលហ្នឹងខ្ញុំនៅធ្វើទាហានទៅប៉ៃលិនខ្ញុំអត់មានទៅរកបងស្រីខ្ញុំ។

ក៖ សំរាប់លោកពូផ្ទាល់កាលនៅក្មេងលោកពូចូលចិត្តធ្វើអ្វីលេងកំសាន្តជាមួយពួកគាត់ទេ។

ខ៖ អត់ដែលលេងស្និតស្នាលជាមួយពួកគាត់ទេព្រោះអីពីរបបរពុលពតមកយើងបែកគ្នាអត់ដែលបាននៅស្និតស្នាលជាមួយបងប្អូន។

ក៖ អញ្ចឹងទាក់ទងហ្នឹងឪពុកវិញឪពុករបស់លោកពូឈ្មោះអីដែល។

ខ៖ ឈ្មោះសុខ កែម។

ក៖ ចុះម្ដាយ។

ខ៖ ឈ្មោះបុណ្យ លី។

ក៖ អ្នកម្ដាយប្រកបរមុខរបបរអីដែរ។

ខ៖ គាត់ជាកសិករ។

ក៖ ចុះឪពុក។

ខ៖ ដូចគ្នា។

ក៖ អរគុណលោកពូទាក់ទងហ្នឹងលក្ខណះរបស់គាត់ពួកគាត់ទាំងពីរជាមនុស្សបែបណាដែរ។

ខ៖ បើនិយាយទៅឪពុកខ្ញុំ ខ្ញុំកើតមកវាមិនទាន់ស្គាល់ច្បាស់របៀបម៉េចទេប៉ុន្តែគាត់បើតាមចាស់ៗនិយាយគាត់ជាមនុស្សម្នាក់ដែលចូលចិត្តទទួលទានស្រាហើយពេលដែលគាត់ស្លាប់ក៏ពិសាស្រាដែរគាត់ស្រវឹងក៏លុងទឹកស្រវឹងស្រាគាត់ដើរឆ្លងទឹកមិនជ្រៅទេទឹកក្រោមជង្គុយទឹកខែប្រាំងតែម្ដាយខ្ញុំវិញគាត់ស្លាប់ដោយសារលើសឈាម។

ក៖ កាលជំនាន់ហ្នឹងអត់មានថ្នាំព្យាបាលទេ។

ខ៖ បាទ!។

ក៖ អរគុណច្រើនលោកពូសំរាប់ការចែកចាយអំពីប្រវត្តិអញ្ចឹងលោកពូដឹងថាគាត់ទាំងពីកើតនៅឯណាទេ។

ខ៖ ខ្ញុំដូចជាមិនដឹងច្បាស់ដែលហ្នឹងខ្ញុំកើតមកឃើញគាត់នៅស្រុកហ្នឹងតែម្ដង។

ក៖ អញ្ចឹងគាត់កើតឆ្នាំអីគេ។

ខ៖ខ្ញុំ អត់ដឹងច្បាស់ដែល។

ក៖ អញ្ចឹងពួកគាត់ទាំងពីរប្រកបរមុខរបបរចិញ្ចឹមជីវិតដោយធ្វើស្រែចំការណោះ។ អញ្ចឹងក្រៅពីការងារស្រែចំការពួកគាត់ធ្វើទៀតសំរាប់ចិញ្ចឹមជីវិត។

ខ៖ គាត់មានប៉ុណ្ណឹងមិនដែលធ្វើអីទៀតទេ។

កៈ ជីដូនជីតាវិញ ជីដូនជីតាខាងឪពុកឈ្មោះអីដែលលោកពូ។

ខៈ បើនិយាយចំទៅខ្ញុំស្គាល់ឈ្មោះតា យម។

កៈ តា យម។ ចុះយី។

ខៈ អត់ស្គាល់។តាឈ្មោះសុខ សុំទោសភ្លេចតាឈ្មោះសុខ។

កៈ ពូកគាត់រស់នៅខេត្តណាដែល។

ខៈ ទាំងពីកើតជាគាត់រស់នៅដូចភូមិឃុំដែលខ្ញុំរៀបរាប់ហ្នឹងស្រុកបាណន់ ខេត្តបាត់ដំបងប៉ុន្តែខ្ញុំបានស្គាល់តែយីខ្ញុំមួយទេ។ យីខាងឪពុក។

កៈ ស្គាល់តែយីតាខាងឪពុកចុះយីតាខាងម្តាយវិញ។

ខៈ អត់ចាំ។

កៈ អត់ចាំ។

ខៈ អត់ឃើញទាំងអស់កើតមកទាន់ទេ។ ស្គាល់តែយីខាងឪពុកមួយទេ។

កៈ ធ្លាប់មានគេនិយាយឪពុកម្តាយរបស់លោកពូមាននិយាយប្រាប់អត់ថាយីតាគាត់ធ្វើអីគាត់ទៅណា។

ខៈ អត់ដែរ។

កៈ ចុះទាក់ទងហ្នឹងក្រុមគ្រួសារវិញម៉ងតើក្រុមគ្រួសាររបស់លោកពូរស់នៅខេត្តអីដែលរស់នៅទីនេះអស់រយៈពេលប៉ុន្មានហើយ។

ខៈ ខ្ញុំរស់នៅទីនេះតាំងពីឆ្នាំ១៩៩៧។

កៈ មុខហ្នឹងលោកពូនៅទីពីមុខលោកពូនៅទីណាដែល។

ខៈ មុខហ្នឹងនៅទីនេះខ្ញុំរស់នៅសែន។

កៈ អញ្ចឹងលោកពូមានសាច់ញាតិរបស់លោករស់នៅក្រៅប្រទេសទេ។

ក៖ អត់មានទេ។ ខ្ញុំចង់សួរទាក់ទងទៅហ្នឹងអាពាហ៍ពិពាហ៍វិញម្តងតើអាពាហ៍ពិពាហ៍ប្រពន្ធរបស់លោកពូឈ្មោះអីដែល។

ខ៖ កាលពីតខ្ញុំមានកូនទីមួយកែម សាសុទ។ គាត់បានស្លាប់កាលហ្នឹងខ្ញុំការនៅឆ្នាំ១៩៩៥ដល់១៩៩៨គាត់ស្លាប់បន្ទាប់មកឆ្នាំ២០១១ខ្ញុំបានការប្រពន្ធមួយទៀតឈ្មោះងឿក ងោង។ គាត់ជាជនពិការដូចខ្ញុំដែលសព្វថ្ងៃខ្ញុំមានកូនពីរក្នុងបន្ទុកក្នុងគ្រួសារ។

ក៖ អញ្ចឹងមានកូនពីរនាក់ហើយណេ៎ពូណោះ។

ខ៖ បាទ!។

ក៖ អរគុណហើយអញ្ចឹងអាពាហ៍ពិពាហ៍ទាក់ទងហ្នឹងអាពាហ៍ពិពាហ៍ហ្នឹងទាក់ទងទៅហ្នឹងប្រពន្ធបច្ចុប្បន្នតើបានស្គាល់គ្នាដោយរបៀបណាដែល។

ខ៖ បានស្គាល់គ្នានៅក្នុងមណ្ឌលអង្គការHI បានស្គាល់នៅក្នុងមណ្ឌលហ្នឹង។ ខ្ញុំដំបូងជាកីឡាកប្រចាំ HI ហើយប្រពន្ធខ្ញុំគាត់ធ្វើការនៅអង្គការជនពិការហើយយើងបានស្គាល់គ្នាយើងបានលេងកីឡាជាមួយគ្នាយើងបានស្រលាញ់គ្នា។ យើងព្រមព្រៀងរៀបការមិនមានអ្នកណាចាប់បង្ខំ។

ក៖ ហើយកាលហ្នឹងខាងស្រីគេទាដណ្តាការប៉ុន្មាន។

ខ៖ អត់ទេព្រោះថាយើងអត់ដូចគ្នាធ្វើតែតាមដំណើរទៅ។

ក៖ ដល់ភាសាវិញម្តងក្រៅពីភាសាខ្មែរលោកពូមានចេះភាសាអីផ្សេងទៀតទេ។

ខ៖ អត់ទេគ្មានចេះភាសាអីផ្សេងទៀតទេចេះតែភាសាខ្មែរ។

ក៖ ចុះភាសាថៃ។

ខ៖ ចេះបានតែមួយម៉ាត់ពីរម៉ាត់ខ្ញុំមកនិយាយថាចេះ។

ក៖ អញ្ចឹងទាក់ទងទៅហ្នឹងខ្សែជីវិតនិងការសិក្សាវិញម្តង។ លោកពូបានសិក្សានៅសាលាណា។

ខ៖ បើនិយាយពីការសិក្សាវិញដូចសម្តេចហ៊ុនសែននិយាយកាលពី១៩៧៩មកសាលាគ្មានទេខ្ញុំបានរៀនថ្នាក់ទី៧ហើយចូលបំរើកងព័ទ្ធកាលឆ្នាំ១៩៨៣អញ្ចឹងខ្ញុំមិនត្រូវបានរៀនតទៅទៀតទេតែខ្ញុំធ្វើទាហានខ្ញុំព្យាយាមរៀនពីមិត្តភក្រ័ដែលបងៗដែលគាត់ចេះជាងយើងអញ្ចឹងយើងសុំគាត់រៀនទៅចេះអានបានច្រើនជាងអ្វីដែលយើងរៀននៅសាលាបានមើលឈ្មោះដូចអង់គ្លេសយើងអាចមើលឈ្មោះបានតែអោយយើងចេះយើងមិនចេះទេ។

ក៖ លោកពូចាំឈ្មោះសាលាទេ។

ខ៖ អ៎! សាលានៅស្រុកខ្ញុំហ្នឹងកាលហ្នឹងមិនមានឈ្មោះថាសាលាអីទេគ្រាន់តែថានៅក្នុងភូមិខ្ញុំមិនមានឈ្មោះថាសាលាអីទេកាលនោះមិនមានទេឆ្នាំ៨០ជាងនៅតាមជនបទអត់មានអីទាំងអស់។

ក៖ កាលពីលោកពូនៅយុវ័យនៅកំលោះលោកពូនមានមិត្តភក្រច្រើនទេ។

ខ៖ មិត្តភក្រមិនច្រើនប៉ុន្មានទេខ្ញុំដឹងក្តីមកខ្ញុំចាប់ផ្តើមធ្វើសង្គ្រាមរហូតមានមិត្តធ្វើទាហានជាមួយគ្នាជាជនពិការច្រើនដែរ។

ក៖ លោកពូមានចាំឈ្មោះពួកគាត់ទេ។

ខ៖ អារឿងឈ្មោះយើងអាចរៀបរាប់បានទាំងអស់បានទេជួនកាលភ្លេចជួនកាលឃើញហើយគ្រាន់តែប្រហែលមុខៗគ្រាន់តែសួរណែនាំទៅបានធ្លាប់តស៊ូជាមួយគ្នាប្រវត្តិ។

ក៖ ពួកគាត់ភាគច្រើនពួកគាត់នៅខេត្តបាត់ដំបងរឺក៏នៅខេត្តផ្សេងៗ។

ខ៖ នៅខេត្តផ្សេងៗនៅខេត្តកណ្តាល ព្រៃវែង ស្វាយរៀង កំពងចាមនិយាយអោយចំសឹងតែគ្រប់ខេត្តហើយបើយើងធ្លាប់ស្គាល់គ្នាហើយរៀងភ្លេចខ្លះអីខ្លះទៅនៅចាំខ្លះ។

ក៖ អញ្ចឹងសំរាប់លោកពូផ្ទាល់លោកពូប្រកបរមុខរបបរអីនៅក្នុងក្រុមគ្រួសាររបស់លោកពូ។

ខ៖ បន្ទាប់មកខ្ញុំជាកម្មករជាគេធ្វើការនៅរោងចក្រដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារយើងប្រពន្ធខ្ញុំនៅផ្ទះប្រកបការងារដេរអោយគេអញ្ចឹង។

ក៖ ក្រៅពីមុខរបបរោងចក្រលោកពូមានធ្វើអីក្រៅម៉ោងទៀតទេដែលអាចរកថវិការបានទេ។

ខ៖ អត់មានអីទាំងអស់ចេញមកពេលល្ងាចពីដើមយើងធ្វើការសំរាក់ថ្ងៃសៅរ៍ផែនការគេថ្មីធ្វើការដល់ម៉ោង៩ចេញតែធ្វើថ្ងៃសៅរ៍ពីដើមធ្វើដល់ម៉ោង៥ថ្ងៃសៅរ៍អាទិត្យសំរាក់តែឥឡូវយើងធ្វើការដល់ថ្ងៃសៅរ៍ម៉ោង៩បានចេញគ្រប់ពេល។

ក៖ ចុះអត់មានថែមម៉ោងគេអោយប្រាក់ខែយើងប៉ុន្មាន។

ខ៖ បើយើងស៊ីឡូរអោយយើងផ្សេងពីនៅធម្មតាដូចថាថ្ងៃសៅរ៍ក៏ដោយតែគេថែមម៉ោងអញ្ចឹងគេគិតថាមួយឡូយើងប៉ុន្មានពីរពាន់អញ្ចឹងយើងត្រូវបានពីរពាន់ប្រាំ។

ក៖ អញ្ចឹងទាក់ទងពីខ្សែជីវិតទាំងពីក្មេងរហូតមកដល់ពេលនេះលោកពូមានឃើញថាមានការផ្លាស់ប្រែអីទេនៅក្នុងជីវិត។

ខ៖ សំរាប់ជីវិតដូចជាគ្នាការកែប្រែអីទេក្រលំបាកមានតែធម្មតាៗ។

ក៖ នៅតែខ្វះខាត។

ខ៖ បាទ! នៅតែខ្វះខាតហើយនៅពេលនោះវាមិនមានតែគ្រាន់តែពិការជំបូងយើងគ្មានម៉ូតូជិះតែឥឡូវយើងមានជីវិតខុសប្លែកគ្នាអញ្ចឹងហើយមុខហ្នឹងមានម៉ូតូជិះយើងបង់រំលោះគេទំនាំតែបាន។

ក៖ សន្សំបន្តិចម្តង។

ខ៖ បាទ!។

ក៖ អញ្ចឹងទាក់ទងទៅហ្នឹងមុខម្ហូបវិញលោកពូតាំងពីក្មេងដល់ឥឡូវលោកពូមានម្ហូបណាជក់ចិត្តជិតអារម្មណ៍ដែលទេ។

ខ៖ ខ្ញុំម្ហូបដែលខ្ញុំចំនូលជាគេមានតែស្ងោម្ជូរមួយទេក្រៅពីហ្នឹងគ្មានតែរួចមួយពេលៗ។

ក៖ ហើយទាក់ទងទៅហ្នឹងចំរៀងវិញលោកពូចូលចិត្តចំរៀងប្រភេទណាដែល។

ខ៖ សំរាប់ខ្ញុំចូលចិត្តចំរៀងសម័យពីដើមបទពីដើមរាំវង់អីចូលចិត្តចាប៊ីដងវែងអី។

ក៖ ទាក់ទងហ្នឹងឧបករណ៍ភ្លេងវិញពូលោកមានអ្នកចេះលេងឧបករណ៍ភ្លេងទេ។

ខ៖ អត់គ្មានអ្នកណាចេះលេងអីសោះ។ សូម្បីតែខ្ញុំក៏មិនចេះលេងដែល។

ក៖ ផ្ទះរបស់លោកពូពីដើមមានលក្ខណៈម៉េចដែល។

ខ៖ ផ្ទះខ្ញុំពីដើមខ្ញុំគ្រាន់តែកើតមកវាចាប់ផ្ដើមផ្សេងសង្គ្រាមមានហើយប៉ុន្តែផ្ទះខ្ញុំដូចមិនធំទេធម្មតាផ្ទះស្បៅអីតែផ្ទះពីដើមនៅជនបទមានសសរ៩ដើមអញ្ចឹង។

ក៖ លោកពូសាងសងខ្លួនឯងរឺក៏ម្ដាយជាអ្នកសាងសងអោយ។

ខ៖ អាហ្នឹងម្ដាយខ្ញុំឥឡូវនេះគ្មានទេ។

ក៖ ហើយសំភារអីជញ្ជាំង។

ខ៖ ជញ្ជាំងស្បៅកាលហ្នឹងដំបូលមានតែស្បៅ។

ក៖ សំរាប់លោកពូផ្ទាល់បានរៀនជំនាញអីតពីឪពុកម្ដាយទេ។

ក៖ អត់មានបានរៀនជំនាញអីពីគាត់ទេ។ អញ្ចឹងទាក់ទងនិងបញ្ហានោធៅក្នុងជីវិតវិញលោកពូតាំងពីដើមរហូតដលឥឡូវនេះលោកពូពិបាកចិត្តខ្លាំងមានទេ។

ខ៖ មានច្រើនណាស់តាំងពីខ្ញុំនៅរៀនខ្ញុំពិបាកខ្ញុំឈឺស្គមហើយថ្ងៃមួយភ្លឹកមិនដឹងខ្លួនទេដើរទៅដល់លើកទឹកស្រូវធឹកប៉ុន្តែខ្ញុំមិនបានដឹងខ្លួនគេយកខ្ញុំទៅពេទ្យហើយតាំងពីហ្នឹងមកលេងឈឺហើយបន្ទាប់មកចាប់ផ្ដើមមានបញ្ហការប្រពន្ធទី២មានបញ្ហាឡានបុកខ្ញុំគ្រោះថ្នាក់ចរាចរណ៍សន្លាប់មិនដឹងខ្លួនដែរបានគេយកមកអ្នកដែលបុកខ្ញុំហ្នឹងគេយកខ្ញុំមកពេទ្យព្យាបាលជំងឺហើយរហូតមកប៉ុន្មានថ្ងៃនេះងាប់មួយចំហៀងខ្លួនទៀត។

ក៖ លោកពូអាចលើកដៃបានទេ។

ខ៖ បានលើកបានលើកបានដើរបានធូរគ្រាន់ធ្វើការបានធម្មតាងាប់មួយចំហៀងខ្លួនប្រហែលជាកន្លះខែមកវិញប្រពន្ធខ្ញុំខំច្របាញ់ដើរជុំដៃកមិនចង់រួចណាមួយខ្យាយជើង។

ក៖ អញ្ចឹងមានអីសំរាប់ខំប្រឹងប្រែង។

ខ៖ រាល់ថ្ងៃខ្ញុំខំប្រឹងប្រែង។

ក៖ ខ្ញុំអរគុណលោកពូអញ្ចឹងលោកពូឆ្លងកាត់ពីបានន័យថាយើងជួបឧបសគ្គតែយើងនៅតែប្រឹងប្រែងលោកពូអញ្ចឹងទាក់ទងទៅហ្នឹងសេចក្ដីល្អវិញលោកពូធ្លាប់បានធ្វើអីល្អៗសំរាប់ក្រុមគ្រួសារទេ។

ខ៖ ខ្ញុំគ្មានបានធ្វើអីអាក្រក់ទេតែអារឿងធ្វើអំពើរល្អខ្ញុំមិនហ៊ានអះអាងថាខ្ញុំធ្វើអំពើមួយ។

ក៖ អ្វីដែលលោកពូគិតជាលោកពូសប្បាយចិត្ត។

ខ៖ អ្វីដែលធ្វើអោយខ្ញុំសប្បាយចិត្តបានមានគេលើកទឹកចិត្តខ្ញុំសប្បាយចិត្តណាស់បើសិនជាខ្ញុំស្លរមួយឆ្នាំអោយគេហូបយើងសប្បាយចិត្តបើគេមិនហូបយើងពិបាកចិត្ត។ ខ្ញុំប្រាជ្ញាអន់បើថាមហាជិតាចង់បានអ្វីមួយគឺអត់ខ្លួនឯងចង់បានគឺអត់មានហើយចង់ធ្វើតែមនុស្សល្អប៉ុន្តែខ្ញុំមិនហ៊ានអះអាងថាខ្ញុំជាមនុស្សល្អហើយខ្ញុំក៏មិនដែលទៅវៃគេចេបញ្ចោគេវាមានបន្ទិចបន្តួចពីដើមកាលនៅតូចដល់ពេលខ្ញុំដឹងក្ដីខ្ញុំមិនដែលសូម្បីតែវៃគេនិយាយត្រង់ម៉ងមួយជីវិតខ្ញុំមានវៃកូនតូចមានប៉ុន្តែខ្ញុំសន្យាថាខ្ញុំឈប់វៃកូនខ្ញុំប្រហែល៥ឆ្នាំហើយកូនធំហើយបានឈប់វៃវាអត់ប្រយោជន៍កូនធំគ្រាន់តែប្រមានជាទេមិនវៃទេ។

ក៖ អរគុណលោកពូ ហើយសំរាប់បន្តទៀតលោកពូមានគោលបំណងម៉េចដែរសំរាប់លោកពូផ្ទាល់។

ខ៖ សព្វថ្ងៃមានគោលបំណងមួយចង់បានដីធ្វើលំនៅឋានខ្លួនឯងហើយទុកអោយបំណងមានតែមួយហ្នឹងទេមិនចង់បានអីទៀតទេ។

ក៖ ចង់ទិញដីតំលៃសមរម្យ។

ខ៖ បាទ! ចង់ទិញដីតំលៃសមរម្យហើយសំរាប់ខ្លួនឯងខឹតខំប្រឹងប្រែងបើយើងបានធូរធាយើងអាចបង់រំលោះដីអីបានតិចតួច។

ក៖ អរគុណច្រើនសំរាប់ការចែកចាយហើយខ្ញុំចង់ជំរាបថាខ្ញុំមកពីសាលាវិទ្យាល័យនៅអាមេរិចហើយសាលាវិទ្យាល័យនោះបានរៀបចំជាក្រុមដើម្បីរក្សាប្រវិត្តរបស់ប្រជាជនកម្ពុជាយើងហើយគោលបំណងដើម្បីរក្សានេះទុកអោយកូនចៅជំនាន់ក្រោយដើម្បីអោយគាត់បានដឹងពីហើយណាមួយនិស្សិតហើយពួកខ្ញុំចង់ពីបទពិសោធន៍របស់បងប្អូនទាំងឡាយនៅក្នុងប្រទេសកម្ពុជាផងដែរអញ្ចឹងជាចុងក្រោយលោកពូមានអីជាសំណូមពររឹមតិយោបលមុខនិងការសំភាសន៍នេះទេ។

ខ៖ ខ្ញុំដូចគ្មានអីសំណូមពរប៉ុន្តែគ្រាន់តែសូមអោយក្រុមហ្នឹងធ្វើការអោយបានរលូនល្អសំរាប់អោយក្មេងជំនាន់ក្រោយគាត់រៀនស្វែងយល់ពីការរស់នៅរបស់ពួកខ្ញុំហ្នឹងតើពួកជំនាន់មុខគេធ្វើយ៉ាងម៉េចអីយ៉ាងម៉េច។

ក៖ អញ្ចឹងលោកពូចង់អោយកូនលោកពូក្លាយទៅជាអីដែល។

ខ៖ ខ្ញុំសព្វថ្ងៃខ្ញុំមិនហ៊ានធានាថាអោយកូនខ្ញុំក្លាយជាអីទេខ្ញុំគ្រាន់តែបើរៀនចេះហើយរកការងារដោយខ្លួនគេនោះចាំចង្អុយប្រាប់ថាអញ្ចេកមួយៗ។

ក៖ ចង់អោយគាត់ចេះដឹងណោះ។

ខ៖ ហ្នឹងហើយ។

ក៖ ជ្រើសរើសអ្វីមួយដែលគាត់អាច។

ខ៖ ហ្នឹងហើយជ្រើសរើសអ្វីមួយដែលជាចំណង់ចិត្តដែលគាត់ចង់ធ្វើយើងរុញគាត់ហើយលើកទឹកចិត្តគាត់ថែម។

ក៖ មានអីទៀតទេ។

ខ៖ អស់ហើយ។

ក៖ អញ្ចឹងសូមអរគុណលោកពូ។

ខ៖ អរគុណដែលបានសំភាសន៍៕